ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៥ សហវ.[illegible]

# សារាចរណែនាំ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដំណាក់កាលទី២

ដើម្បីអនុវត្តតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងធានាដល់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Register Management Information System-SARMIS) ជាដំណាក់កាលបន្តបន្ទាប់ដើម្បីដាក់ឱ្យអនុវត្តជាផ្លូវការដល់គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់។

កន្លងមក ក្នុងដំណាក់កាលទី១ ប្រព័ន្ធ SARMIS ត្រូវបានដាក់ឱ្យអនុវត្ត ចំពោះអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលជាក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត និងនីតិបុគ្គលសាធារណៈ កាលពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១ តាមរយៈសារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងដំណាក់កាលទី២ ប្រព័ន្ធ SARMIS ត្រូវដាក់ឱ្យអនុវត្ត ចំពោះអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលជារដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០២៣ តទៅ។

ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋជារដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវអនុវត្តប្រព័ន្ធ SARMIS ដំណាក់កាលទី២ ដូចតទៅ÷

១-ត្រូវបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋនៃបញ្ជីសារពើភណ្ឌរបស់ខ្លួនតាមរយៈប្រព័ន្ធ SARMIS ដែលផ្តល់ដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២.ត្រូវបញ្ជូនសៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោលរៀងរាល់ ៥ ឆ្នាំម្តង និងសៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋនៅចន្លោះរយៈពេល ៥ ឆ្នាំ នៃឆ្នាំគោល ដែលត្រូវបានបោះពុម្ពចេញពីប្រព័ន្ធ SARMIS មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយអនុលោមតាមអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាធរមាន ដោយភ្ជាប់មកជាមួយនូវទិន្នន័យដែលបានបញ្ចូលក្នុងប្រព័ន្ធ SARMIS។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ទទួលបានសារាចរណែនាំនេះ គ្រប់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវសហការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២៣ តទៅ។

ថ្ងៃចន្ទ ៩កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល</u>** ÷

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

-រដ្ឋបាលរាជធានីភ្នំពេញ និងខេត្ត

-រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ